ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០៩-០៧៤ ប្រ.ក

# ប្រកាស
## ស្តីពី
## លក្ខណៈសំគាល់នៃក្រដាសប្រាក់ប្រភេទ ២០០០០ រៀល គំរូថ្មី

អនុលោមតាមអនុក្រឹត្យលេខ ៥១ អនក្រ.បក របស់រាជរដ្ឋាភិបាល ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការចេញផ្សាយក្រដាសប្រាក់ប្រភេទ ២០០០០ រៀល គំរូថ្មីដាក់ឱ្យចរាចរក្នុងព្រះរាជាណាចក្រកម្ពុជា បានបំពេញឱ្យប្រាក់រៀលមានរចនាសម្ព័ន្ធប្រភេទប្រាក់កាន់តែសមស្រប រួមចំណែកក្នុងការលើកកំពស់ប្រសិទ្ធភាព និងភាពងាយស្រួលដល់ប្រជាជនយើង ក្នុងការចាយវាយនិងរក្សាទុករូបិយវត្ថុជាតិ ធនាគារជាតិនៃកម្ពុជា សូមប្រកាសផ្សព្វផ្សាយនូវលក្ខណៈសម្គាល់សំខាន់ៗនៃក្រដាសប្រាក់ប្រភេទ ២០០០០ រៀល គំរូថ្មីនេះ មានដូចខាងក្រោម :

### ក_លក្ខណៈទូទៅ

- បណ្តោយ ១៥០មម និងទទឹង ៧០មម
- ពណ៌ចំបងៗ គឺស៊ីជម្ពូ និងពណ៌ខៀវ ។

### ខ_លក្ខណៈសម្គាល់នៃក្រដាសប្រាក់

១_ផ្ទៃខាងមុខ :

- ផ្ទៃកកណ្តាលប៉ែកខាងស្តាំត្រូវបានរំលេចឡើងនូវព្រះឆាយាល័ក្ខណ៍នៃ **សម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងមានអក្សរ "**អ្នកក្លែងក្រដាសប្រាក់នឹងត្រូវផ្តន្ទាទោសតាមច្បាប់** " នៅគែមខាងក្រោម រីឯប៉ែកខាងឆ្វេងមានលេខ "**២០០០០** " នៅផ្ទៃខាងលើ បន្ទាប់មក គឺជាហត្ថលេខារបស់ទេសាភិបាល និងអគ្គបេឡាលេខ-មាលា បោះពុម្ពដោយទឹកខ្មៅពណ៌ខ្មៅ និងនៅខាងក្រោមបង្អស់មានរូបចម្លាក់នាគក្បាលប្រាំព្រមទាំងអក្សរ "**ពីរម៉ឺនរៀល** " ។

- នៅផ្ទៃកខាងស្តាំ ជ្រុងខាងលើមានអក្សរ "**ធនាគារជាតិនៃកម្ពុជា** " បន្ទាប់មកមានលេខ-មាលា បោះពុម្ពដោយ ទឹកខ្មៅពណ៌ក្រហម លេខ " **២០០០០** " ពណ៌ទឹកប្រាក់ និងជ្រុងខាងក្រោមមានលេខអន្តរជាតិ " **20000** " ។

- នៅផ្ទៃកខាងឆ្វេងនៃធនប័ត្រ មានហូឡូក្រាម 9 ᵐᵐ លាតសន្ធឹកពីគែមខាងលើដល់គែមខាងក្រោម ។ នៅលើហូឡូក្រាមមានសំណុំរូបភាពប្រែប្រួលមួយចំនួន បើមើលចំពីលើឃើញជារូបសញ្ញាធនាគារជាតិនៃកម្ពុជា និងមើលបញ្ឆិតឃើញ ជាលេខ " ២០០០០ " ។

ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ២២-២៤ មហាវិថី ព្រះនរោត្តម រាជធានីភ្នំពេញ, ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ . ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

២.ផ្ទៃខាងខ្នង :

- លើផ្ទៃខាងខ្នងនៃក្រដាសប្រាក់  មានរំលេចឡើងនូវរូបភាពប្រាសាទអង្គរធំទាំងមូលមើលបញ្ឆិតពីលើ  និងរូបចម្លាក់ព្រហ្មមុខបួននៃប្រាសាទបាយ័ន ។

- នៅផ្ទៃកកណ្ដាល ខាងលើមានអក្សរ " **ធនាគារជាតិនៃកម្ពុជា** "និងខាងក្រោមមានអក្សរ " **ពីរម៉ឺនរៀល** " ។

- នៅផ្ទៃកខាងស្ដាំ  ជ្រុងខាងលើមានលេខអន្តរជាតិ " **20000** " បោះពុម្ពតាមបន្ទាត់បញ្ឈរ  និងជ្រុងខាងក្រោមមានលេខ " ២០០០០ " ។

- នៅផ្ទៃកខាងឆ្វេង  ជ្រុងខាងលើមានអក្សរ " NATIONAL BANK OF CAMBODIA " ព្រមទាំងមានលេខសម្គាល់ឆ្នាំបោះផ្សាយនៅពីក្រោមអក្សរនោះ និងនៅជ្រុងខាងក្រោមមានលេខ " ២០០០០ " ។

ក្រដាសប្រាក់ប្រភេទ ២០០០០ រៀល  គំរូថ្មីនេះ  ត្រូវបានបោះផ្សាយដាក់ឱ្យចរាចរចាប់ពីថ្ងៃចេញប្រកាសនេះ  តទៅទន្ទឹមគ្នាជាមួយនឹងក្រដាសប្រាក់គ្រប់ប្រភេទដែលកំពុងធ្វើចរាចរសព្វថ្ងៃ  ។  សាធារណជនទាំងឡាយត្រូវពិនិត្យពិច័យក្រដាសប្រាក់នេះ  ឱ្យបានច្បាស់លាស់  ដោយផ្អែកតាមលក្ខណៈសម្គាល់សំខាន់ៗដូចបានរៀបរាប់ខាងលើ  ដើម្បីជៀសវាងការភ័ន្តច្រឡំ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ ឧសភា  ឆ្នាំ ២០០៨

**ទេសាភិបាល**

**ជា_ចាន់តូ**